ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១២៩ រ៉ែ.ថបប.ប្រក.

# ប្រកាស
## ស្ដីពី
## ការគ្រប់គ្រងការនាំចូលនិងការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីវិធាននៃការគ្រប់គ្រងការនាំចូលនិងការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ក្នុងគោលបំណងដើម្បីៈ

- បង្កើនប្រសិទ្ធភាពលើការគ្រប់គ្រងសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ប្រកបដោយសុវត្ថិភាព សន្តិសុខ តម្លាភាព និងគណនេយ្យភាព

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- ការពារសុខភាពមនុស្ស សត្វ និងបរិស្ថាន ឱ្យជៀសផុតពីឥទ្ធិពលគ្រោះថ្នាក់ ដែលអាចបង្កឡើងដោយសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម និង
- លើកកម្ពស់ការចូលរួមអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាពាក់ព័ន្ធនឹងសុវត្ថិភាពវិទ្យុសកម្ម និងសន្តិសុខវិទ្យុសកម្ម ក្នុងការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងការនាំចូលនិងការប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្មផ្នែកស៊ីវិលគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែជាផលិតផលឱសថសម្រាប់ព្យាបាលរោគមហារីកដែលស្ថិតនៅក្រោមបទប្បញ្ញត្តិដោយឡែក ឬមានការកំណត់នៅក្នុងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យ ដូចតទៅ៖

**ប្រភពវិទ្យុសកម្ម** សំដៅដល់សារធាតុ សម្ភារ និងឧបករណ៍បរិក្ខារទាំងឡាយណាដែលបញ្ចេញវិទ្យុសកម្ម។

**ផ្នែកស៊ីវិល** សំដៅដល់ការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម រួមទាំងបច្ចេកវិទ្យា និងទីតាំងពាក់ព័ន្ធ ក្នុងគោលដៅសន្តិភាព។

**វិទ្យុសកម្ម** សំដៅដល់ថាមពលដែលបញ្ចេញក្នុងទម្រង់ជារលកអេឡិចត្រូម៉ាញ៉េទិច (កាំរស្មីហ្គាម៉ា ឬកាំរស្មីអ៊ិច) ឬភាគល្អិត (អាល់ហ្វា បេតា ឬណឺត្រុង) ដែលមានកម្លាំងគ្រប់គ្រាន់អាចធ្វើអ៊ីយ៉ុងកម្មនៅពេលដែលឆ្លងកាត់មជ្ឈដ្ឋានណាមួយ។

**សន្តិសុខវិទ្យុសកម្ម** សំដៅដល់ការអនុវត្តសកម្មភាពនិងវិធានការចាំបាច់ទាំងឡាយណា ដើម្បីទប់ស្កាត់ រាវរក និងឆ្លើយតបទៅនឹងការប៉ុនប៉ងលួចយក បំផ្លិចបំផ្លាញ ផ្ទេរចេញដោយខុសច្បាប់ ឬសកម្មភាពទុច្ចរិតផ្សេងៗ លើរូបវន្តសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ឬទីតាំងពាក់ព័ន្ធ។

**សារធាតុវិទ្យុសកម្ម** សំដៅដល់ធាតុទាំងឡាយណា រួមទាំងអ៊ីសូតូប និងសមាសធាតុរបស់វា ដែលសម្ព័ន្ធអាតូមគ្មានលំនឹង និងអាចបំបែកដោយឯកឯង ហើយប្លែងជាធាតុផ្សេងទៀត ដោយបញ្ចេញវិទ្យុសកម្ម ដែលបាតុភូតនេះអាចកើតឡើងដោយធម្មជាតិ ឬដោយដំណើរការផលិតកម្ម។

**សុវត្ថិភាពវិទ្យុសកម្ម** សំដៅដល់ការអនុវត្តសកម្មភាពនិងវិធានការចាំបាច់ទាំងឡាយណាសម្រាប់ការពារសុខភាពមនុស្ស សត្វ និងបរិស្ថាន ឱ្យជៀសផុតពីការទទួលរងឥទ្ធិពលគ្រោះថ្នាក់វិទ្យុសកម្ម ព្រមទាំងទប់ស្កាត់គ្រោះថ្នាក់វិទ្យុសកម្មដែលអាចកើតមានឡើងដោយយថាហេតុ និងកាត់បន្ថយផលប៉ះពាល់នៅពេលមានគ្រោះថ្នាក់វិទ្យុសកម្មកើតឡើង។

## ជំពូកទី ២
## បែបបទនិងនីតិវិធីនៃការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត

**ប្រការ៤.-**

នីតិបុគ្គល ដែលមានបំណងនាំចូលនិងប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតពីក្រសួងរ៉ែនិងថាមពល។

**ប្រការ៥.-**

នីតិបុគ្គល ដែលមានបំណងស្នើសុំលិខិតអនុញ្ញាតនាំចូលនិងប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម អាចទទួលបានពាក្យស្នើសុំ ឬព័ត៌មានបន្ថែមតាមរយៈការិយាល័យច្រកចេញចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ឬតាមរយៈគេហទំព័រ ដែលមានអាសយដ្ឋាន www.mme.gov.kh។

**ប្រការ៦.-**

នីតិបុគ្គល ដែលមានបំណងស្នើសុំលិខិតអនុញ្ញាតនាំចូលសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ត្រូវបំពេញពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ៧.-**

នីតិបុគ្គល ដែលមានបំណងស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ត្រូវបំពេញពាក្យស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៨.-**

ពាក្យស្នើសុំទាំងអស់ត្រូវដាក់នៅការិយាល័យច្រកចេញចូលតែមួយនៃក្រសួងរ៉ែនិងថាមពល នៅរៀងរាល់ថ្ងៃធ្វើការ និងម៉ោងធ្វើការ។

មន្ត្រី ដែលទទួលពាក្យស្នើសុំនៅច្រកចេញចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ត្រូវធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់ភាពពេញលេញនៃពាក្យស្នើសុំនីមួយៗ រួមទាំងសំណុំឯកសារពាក់ព័ន្ធដែលភ្ជាប់មកជាមួយ។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមានភាពពេញលេញ ត្រូវចេញសលាកបត្រទទួលពាក្យជូនអ្នកដាក់ពាក្យស្នើសុំតាមទម្រង់ដែលបានកំណត់ដោយក្រសួងរ៉ែនិងថាមពល។

## ជំពូកទី ៣

## លក្ខខណ្ឌនៃការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម

**ប្រការ៩.-**

នីតិបុគ្គល ដែលទទួលបានលិខិតអនុញ្ញាតប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- គោរពតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាពវិទ្យុសកម្មនិងសន្តិសុខវិទ្យុសកម្មជាតិនិងអន្តរជាតិនានាក្នុងការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម

- មានមន្ត្រី ឬបុគ្គលិក ឬកម្មករនិយោជិតដែលទទួលខុសត្រូវមានជំនាញការពារសុវត្ថិភាពវិទ្យុសកម្ម និងសន្តិសុខវិទ្យុសកម្មយ៉ាងតិច ០១រូប
- ផ្តល់របាយការណ៍ និងទិន្នន័យកម្រិតវិទ្យុសកម្មសម្រាប់មន្ត្រី ឬបុគ្គលិក ឬកម្មករនិយោជិតទាំងអស់ ដែលប្រតិបត្តិការផ្ទាល់ជាមួយនឹងសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម មកអគ្គនាយកដ្ឋានថាមពលនៃក្រសួងរ៉ែនិងថាមពល រៀងរាល់ ០២ (ពីរ) ខែ ម្តង ជាចាំបាច់
- អនុញ្ញាតឱ្យមន្ត្រីជំនាញបច្ចេកទេសរបស់អគ្គនាយកដ្ឋានថាមពល នៃក្រសួងរ៉ែនិងថាមពល ចុះត្រួតពិនិត្យ វាយតម្លៃ និងផ្ទៀងផ្ទាត់លើលក្ខខណ្ឌសុវត្ថិភាពវិទ្យុសកម្មនិងសន្តិសុខវិទ្យុសកម្ម ក្នុងការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្មនៅទីតាំងប្រើប្រាស់ ឬរក្សាទុក តាមការចាំបាច់
- ជូនដំណឹងមកមន្ត្រីជំនាញបច្ចេកទេសរបស់អគ្គនាយកដ្ឋានថាមពល នៃក្រសួងរ៉ែនិងថាមពល ជាបន្ទាន់ ក្នុងករណីមានការបាត់បង់ ការលួចយក ឬចេតនាក្នុងការបំផ្លិចបំផ្លាញរូបវន្តសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្មពីទីតាំងប្រើប្រាស់
- ជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពលក្នុងរយៈពេលមិនលើស ៦០ (ហុកសិប) ថ្ងៃមុនថ្ងៃឈប់ដំណើរការ ឬប្រតិបត្តិការអាជីវកម្មដែលមានប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម និង
- ធ្វើការនាំចេញសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្មត្រលប់ទៅប្រទេសដើម ឬប្រទេសណាមួយផ្សេង បន្ទាប់ពីឈប់ប្រើប្រាស់ ឬអស់សុពលភាពប្រើប្រាស់។

## ជំពូកទី ៤
## បែបបទនិងនីតិវិធី នៃការពិនិត្យនិងសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាត

**ប្រការ១០.-**

អគ្គនាយកដ្ឋានថាមពល នៃក្រសួងរ៉ែនិងថាមពលមានភារកិច្ចពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតទាំងនេះ តាមបែបបទនិងនីតិវិធី ដែលមានកំណត់ដូចខាងក្រោម៖

ក- ពិនិត្យរាល់ឯកសារតាមលក្ខខណ្ឌតម្រូវ ស្របតាមលិខិតបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិបច្ចេកទេសដែលមានជាធរមាន។

ខ- ពិនិត្យទីតាំងស្នើសុំប្រើប្រាស់ ឬទីតាំងពាក់ព័ន្ធជាក់ស្តែង ដើម្បីធ្វើកំណត់ហេតុនិងរបាយការណ៍វាយតម្លៃលក្ខណៈបច្ចេកទេសសុវត្ថិភាពនិងសន្តិសុខ។

គ- រៀបចំរបាយការណ៍លទ្ធផលនិងរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ដើម្បីពិនិត្យនិងសម្រេច។

**ប្រការ១១.-**

នីតិបុគ្គល ដែលស្នើសុំលិខិតអនុញ្ញាតនាំចូលនិងប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម អាចទទួលបានការឆ្លើយតបជាលាយលក្ខណ៍អក្សរពីការយល់ព្រម ឬការបដិសេធ លើពាក្យស្នើសុំលិខិត

អនុញ្ញាតក្នុងរយៈពេលមិនលើស ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលសំណុំឯកសារគ្រប់គ្រាន់និងពេញលេញ។

## ជំពូកទី ៥
## សុពលភាព នៃលិខិតអនុញ្ញាតនាំចូលនិងប្រើប្រាស់

**ប្រការ១២.-**

លិខិតអនុញ្ញាតនាំចូលសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម មានសុពលភាពមិនលើស ០៦ (ប្រាំមួយ) ខែ។ នីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាត អាចធ្វើការនាំចូលបានតែ ០១ (មួយ) ដងគត់ក្នុងរយៈពេលសុពលភាពនៃលិខិតអនុញ្ញាត។

ក្នុងករណីសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្មមិនត្រូវបានធ្វើការនាំចូលក្នុងរយៈពេលសុពលភាពនៃលិខិតអនុញ្ញាត នីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាត ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតនាំចូលសារជាថ្មី ដោយត្រូវអនុវត្តតាមបែបបទនិងនីតិវិធីកំណត់ក្នុងប្រកាសនេះ។

**ប្រការ១៣.-**

លិខិតអនុញ្ញាតប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម មានសុពលភាព ០២ (ពីរ) ឆ្នាំ។ នីតិបុគ្គល ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបន្តសុពលភាពប្រើប្រាស់ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃ មុនពេលផុតកំណត់សុពលភាព នៅការិយាល័យច្រកចេញចូលតែមួយនៃក្រសួងរ៉ែនិងថាមពលរៀងរាល់ថ្ងៃធ្វើការនិងម៉ោងធ្វើការ។

បែបបទនិងនីតិវិធីនៃការដាក់ពាក្យស្នើសុំ ការពិនិត្យ និងការសម្រេច ត្រូវអនុវត្តដូចប្រការ៨ ប្រការ១០ និងប្រការ១១ នៃប្រកាសនេះ។

គំរូពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតប្រើប្រាស់ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

## ជំពូកទី ៦
## ការផ្លាស់ប្តូរទីតាំងប្រើប្រាស់និងការផ្ទេរសិទ្ធិគ្រប់គ្រង

**ប្រការ១៤.-**

នីតិបុគ្គល ដែលបានទទួលលិខិតអនុញ្ញាតប្រើប្រាស់ ហើយមានបំណងផ្លាស់ប្តូរទីតាំងប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ហើយត្រូវមានការឯកភាពពីក្រសួងរ៉ែនិងថាមពល មុននឹងធ្វើការផ្លាស់ប្តូរទីតាំងប្រើប្រាស់។

**ប្រការ១៥.-**

នីតិបុគ្គល ដែលជាម្ចាស់ថ្មីលើអាជីវកម្ម ឬទីតាំងប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់សារជាថ្មី មកក្រសួងរ៉ែនិងថាមពល ក្នុងរយៈពេលមិនលើស

៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលសិទ្ធិជាម្ចាស់ថ្មី និងត្រូវមានកាតព្វកិច្ចដូចគ្នាក្នុងការអនុវត្ត នូវលក្ខខណ្ឌដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ។

បែបបទនិងនីតិវិធី នៃការដាក់ពាក្យស្នើសុំ ការពិនិត្យ និងការសម្រេច ត្រូវអនុវត្តដូចក្នុងប្រការ៧ ប្រការ៨ ប្រការ១០ និងប្រការ១១ នៃប្រកាសនេះ។

## ជំពូកទី ៧
## កម្រៃសេវាសាធារណៈ

**ប្រការ១៦.-**

នីតិបុគ្គល ដែលដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូល លិខិតអនុញ្ញាតប្រើប្រាស់ ឬលិខិតអនុញ្ញាតបន្តសុពលភាពប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ត្រូវបង់កម្រៃសេវាសាធារណៈ ស្របតាមប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**ប្រការ១៧.-**

នីតិបុគ្គលសាធារណៈ មិនតម្រូវឱ្យបង់កម្រៃសេវាសាធារណៈទេ ប៉ុន្តែត្រូវមានកាតព្វកិច្ចដូចគ្នាក្នុងការអនុវត្តតាមបែបបទ នីតិវិធី និងលក្ខខណ្ឌតម្រូវ ដូចមានកំណត់ក្នុងប្រកាសនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាជាធរមាន។

## ជំពូកទី ៨
## ការពិន័យ

**ប្រការ១៨.-**

បុគ្គលណា ដែលនាំចូលនិងប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដោយគ្មានលិខិតអនុញ្ញាត ត្រូវពិន័យជាប្រាក់ពី ២.៥០០.០០០ (ពីរលានប្រាំរយពាន់) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល។

នីតិបុគ្គលណា ដែលប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដោយផុតសុពលភាពលិខិតអនុញ្ញាតប្រើប្រាស់ ត្រូវពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៣.០០០.០០០ (បីលាន) រៀល។

**ប្រការ១៩.-**

នីតិបុគ្គលណា ដែលបានទទួលលិខិតអនុញ្ញាតនាំចូលនិងប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ហើយមិនអនុវត្តឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពស្របតាមលក្ខខណ្ឌតម្រូវ លក្ខណៈបច្ចេកទេស ឧត្តមានុវត្ត និង/ឬបទដ្ឋានអន្តរជាតិនានាពាក់ព័ន្ធនឹងសុវត្ថិភាពវិទ្យុសកម្មនិងសន្តិសុខវិទ្យុសកម្មនៃការប្រើប្រាស់ ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយរយពាន់) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល។

**ប្រការ២០.-**

ការពិន័យជាប្រាក់ ដូចមានចែងក្នុងប្រការ១៨ និងប្រការ១៩ នៃប្រកាសនេះ មិនធ្វើឱ្យបុគ្គលរួចផុតពីការអនុវត្តនូវកាតព្វកិច្ច និង/ឬទោសទណ្ឌ ដែលបានកំណត់នៅក្នុងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**ប្រការ២១.-**

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានថាមពល ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

ស៊ុយ-សែម

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ០១២៦.រ៉ែ.ថប/ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១
## ស្តីពី
## ការគ្រប់គ្រងការនាំចូលនិងការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម

## ពាក្យសុំលិខិតអនុញ្ញាតនាំចូលសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម
APPLICATION FORM FOR PERMISSION LETTER TO IMPORT OF RADIOACTIVE SUBSTANCES AND RADIOACTIVE SOURCES

| រូបថតបុគ្គលស្នើសុំ<br>Photo of applicant<br>4 x 6 |
|---|

រាល់ព័ត៌មានខាងក្រោមត្រូវបំពេញដោយអ្នកស្នើសុំ The following information is to be filled by the applicant

---

**1. អំពីអ្នកស្នើសុំ Applicant Information**

☐ នីតិបុគ្គលសាធារណៈ Public Legal Entity

ឈ្មោះក្រសួង-ស្ថាប័ន Institution's Name: ............................................................

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ Office's Permanent Address: ............................................................

............................................................

លេខទូរសព្ទទំនាក់ទំនង Telephone No.: ............................ អ៊ីម៉ែល E-mail: ............................

☐ ក្រុមហ៊ុន Company/Firm

ឈ្មោះអ្នកស្នើសុំ Applicant's Name: ............................ ភេទ Sex: ☐ ប្រុស Male ☐ ស្រី Female

សញ្ជាតិ Nationality: ............................ ថ្ងៃខែឆ្នាំកំណើត Date of Birth: ............................

លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន Khmer ID/Passport No.: ............................

អាសយដ្ឋាន Address: ............................................................

............................................................

លេខទូរសព្ទទំនាក់ទំនង Telephone No.: ............................ អ៊ីម៉ែល E-mail: ............................

តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន Position of Applicant in Company/Firm:

☐ ប្រធានក្រុមហ៊ុន Chairman/Managing Director/Director

☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង) Duly representative of company/firm (please attach power of attorney)

នាមករណ៍ក្រុមហ៊ុន Company/Firm's Name: ............................................................

លេខចុះបញ្ជីពាណិជ្ជកម្ម Business Registration No.: ............................................................

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ Office's Permanent Address: ............................................................

............................................................

លេខទូរសព្ទទំនាក់ទំនង Telephone No.: ............................ អ៊ីម៉ែល E-mail: ............................

**2. មធ្យោបាយដឹកជញ្ជូននាំចូល Modes of Import Transportation**

☐ ការដឹកជញ្ជូនតាមផ្លូវអាកាស Transportation by Air

☐ ការដឹកជញ្ជូនតាមផ្លូវទឹក Transportation by Water

☐ ការដឹកជញ្ជូនតាមផ្លូវគោក Transportation by Land

សូមបញ្ជាក់ច្រកនាំចូល Please specify a port of entry: ............................................................

3. **គោលបំណងនៃការនាំចូល Purpose of Import**

☐ ប្រើប្រាស់ Use

គោលបំណងប្រើប្រាស់ Purpose of Use: ..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

អាសយដ្ឋានទីតាំងដែលប្រើប្រាស់ Address of premises at which radioactive substances/sources to be used: ..........................

..........................................................................................................

..........................................................................................................

☐ ជាទីតាំងផ្ទាល់របស់អ្នកស្នើសុំ Owned by Applicant

☐ ជាទីតាំងជួល Rented from

ឈ្មោះម្ចាស់ទីតាំង Name of Owner: ..........................................................................................

អាសយដ្ឋានម្ចាស់ទីតាំង Address of Owner: ..........................................................................................

..........................................................................................................

លេខទូរសព្ទទំនាក់ទំនង Telephone No .: ..........................................................................................

☐ រក្សាទុក Storing

អាសយដ្ឋានទីតាំងដែលរក្សាទុក Address of premises at which radioactive substances/sources to be stored:

..........................................................................................................

..........................................................................................................

☐ ជាទីតាំងផ្ទាល់របស់បុគ្គលស្នើសុំ Owned by Applicant

☐ ជាទីតាំងជួល Rented from

ឈ្មោះម្ចាស់ទីតាំង Name of Owner: ..........................................................................................

អាសយដ្ឋានម្ចាស់ទីតាំង Address of Owner: ..........................................................................................

..........................................................................................................

លេខទូរសព្ទទំនាក់ទំនង Telephone No .: ..........................................................................................

☐ គោលបំណងនាំចូលផ្សេងទៀត សូមបញ្ជាក់ Other purposes of import, please specify:

..........................................................................................................

..........................................................................................................

4. **ព័ត៌មានមន្ត្រី បុគ្គលិក ឬកម្មករនិយោជិតដែលមានជំនាញការពារសុវត្ថិភាពវិទ្យុសកម្ម Details of Radiation Protection and Safety Officer/s**

- ឈ្មោះ Officer's Name: .......................................................... ភេទ Sex: ☐ ប្រុស Male ☐ ស្រី Female

  សញ្ជាតិ Nationality: ........................................... ថ្ងៃខែឆ្នាំកំណើត Date of Birth: ...........................................

  លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន Khmer ID/Passport No.: ...........................................

  តួនាទី Position: ..........................................................................................

  អាសយដ្ឋាន Address: ..........................................................................................

  ..........................................................................................................

  លេខទូរសព្ទទំនាក់ទំនង Telephone No.: ........................................ អ៊ីម៉ែល E-mail: ........................................

  វិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការពារសុវត្ថិភាពវិទ្យុសកម្ម Certificate/s of Training on Radiation Protection and Safety:

  ☐ មាន Yes (សូមភ្ជាប់មកជាមួយ Please attach) ☐ គ្មាន No

  ☐ ផ្សេងៗ Others: ..........................................................................................

- ឈ្មោះ Officer's Name: ................................................................ ភេទ Sex: ☐ ប្រុស Male ☐ ស្រី Female

សញ្ជាតិ Nationality: ........................................................ ថ្ងៃខែឆ្នាំកំណើត Date of Birth: ..........................................

លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន Khmer ID/Passport No.: ..............................................................

តួនាទី Position: ..........................................................................................................................................

អាសយដ្ឋាន Address: ..................................................................................................................................

...........................................................................................................................................................

លេខទូរសព្ទទំនាក់ទំនង Telephone No.: .......................................... អ៊ីម៉ែល E-mail: ..................................................

វិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការពារសុវត្ថិភាពវិទ្យុសកម្ម Certificate/s of Training on Radiation Protection and Safety:

☐ មាន Yes (សូមភ្ជាប់មកជាមួយ Please attach) ☐ គ្មាន No

☐ ផ្សេងៗ Others: .....................................................................................................................................

**5. ឧបករណ៍វាស់កម្រិតវិទ្យុសកម្ម Radiation Survey Meters**

ប្រភេទឧបករណ៍វាស់កម្រិតវិទ្យុសកម្ម Type of Survey Meters:

☐ ណឺត្រុង Neutron ☐ ផូតុង Photon ☐ ផ្សេងៗ Others: ..........................................

ម៉ាក Model: ......................................................................................................................................................

បរិមាណដែលមាន Quantity: ......................................................................................................................

**6. បរិធានតាមដានកម្រិតវិទ្យុសកម្មសម្រាប់បុគ្គលិក Personal Monitoring Dosimeters** ☐ គ្មាន No ☐ មាន Yes (If yes tick bellow)

ប្រសិនបើមាន If yes

☐ Optically Stimulated Luminescence (OSL) ☐ Thermo-Luminescence Dosimeter (TLD)

☐ Radio-Photo Luminescence (RPL) ☐ Active Dosimeter

☐ ផ្សេងៗ Others:.............................................................................................................................

**7. ការគ្រប់គ្រងសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្មដែលឈប់ប្រើប្រាស់ Management of Disused Radioactive Substance/Sources**

☐ នាំត្រលប់ទៅវិញភ្លាមៗបន្ទាប់ពីឈប់ប្រើប្រាស់ Return immediately after disused

☐ រក្សាទុកបណ្តោះអាសន្នសម្រាប់រៀបចំនាំត្រលប់ទៅវិញ Stored temporarily to prepare for returning

អាសយដ្ឋានទីតាំងរក្សាទុកបណ្តោះអាសន្នមុនពេលនាំត្រលប់ទៅវិញ Address of premises at which disused radioactive substance/sources to be stored temporarily before returning: ..................................................................

...........................................................................................................................................................

☐ ជាទីតាំងផ្ទាល់របស់បុគ្គលស្នើសុំ Owned by Applicant

☐ ជាទីតាំងជួល Rented from

ឈ្មោះម្ចាស់ទីតាំង Name of Owner: ...........................................................................................................

អាសយដ្ឋានម្ចាស់ទីតាំង Address of Owner: ..............................................................................................

...........................................................................................................................................................

លេខទូរសព្ទទំនាក់ទំនង Telephone No .: .....................................................................................................

## ៨. ព័ត៌មានសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដែលត្រូវស្នើសុំលិខិតអនុញ្ញាត Details of Radioactive Substances/Sources for Which Permission Letter is Sought

| ប្រភេទប្រភពវិទ្យុសកម្ម<br>Type of Radioactive Sources | ទម្រង់<br>Forms[1] | ប្រភេទបរិភ័ណ្ឌ<br>Type of Installations (Fixed or Mobile)2 | បរិមាណ<br>Quantity | លេខសម្គាល់<br>Serial Numbers (Sources and/or Containers) | កម្រិតវិទ្យុសកម្ម/កាលបរិច្ឆេទវាស់<br>Sources Activity (Bq or Ci )3 / Reference Date | ក្រុមហ៊ុនផលិត<br>Manufacturer and Country of Origin | ក្រុមហ៊ុនផ្គត់ផ្គង់<br>Supplier and Country of Origin |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

(1) Solid, liquid, gas, sealed, unsealed or others (please specify).

(2) ប្រើប្រាស់ជាប្រភេទបរិភ័ណ្ឌជាប់នៅនឹងកន្លែង ឬជាប្រភេទប្រភពចល័ត Use in the type of installations that is fixed or mobile source

(3) Bq = Becquerel, Ci = curie

## ៩. បញ្ជីឈ្មោះមន្ត្រី បុគ្គលិក ឬកម្មករនិយោជិត ដែលប្រតិបត្តិការផ្ទាល់ជាមួយនឹងសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម (List of General Radiation Workers)

| ឈ្មោះ<br>Name | លេខអត្តសញ្ញាណប័ណ្ណ<br>ឬលេខលិខិតឆ្លងដែន<br>ID/Passport No. | ថ្ងៃខែឆ្នាំកំណើត<br>Date of Birth | តួនាទី<br>Position | អតីតភាពការងារ<br>Duration with Business Entity | សុពលភាពវិញ្ញាបនបត្រ<br>បណ្តុះបណ្តាល<br>Validity of Training Certificate | របាយការណ៍កម្រិតវិទ្យុសកម្មបុគ្គល<br>Record of the Personal Dose |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

10. **សំណុំឯកសារតម្រូវឱ្យភ្ជាប់មកជាមួយ Supporting Document Required to be Attached:**

- សម្រាប់នីតិបុគ្គលសាធារណៈ Public Legal Entity:
  - ☐ ច្បាប់ចម្លងវិញ្ញាបនបត្រ ឬឯកសារបញ្ជាក់ពីលក្ខណៈបច្ចេកទេសរបស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដែលចេញដោយក្រុមហ៊ុនផលិត ឬក្រុមហ៊ុនផ្គត់ផ្គង់ A copy of certificate or documents on the technical specifications of radioactive substances/sources issued by manufacturer or supplier company ..........................................០១ ច្បាប់ (1 Copy)
  - ☐ កិច្ចព្រមព្រៀង ឬកិច្ចសន្យា ឬឯកសារបញ្ជាក់ពីក្រុមហ៊ុនផលិត ឬក្រុមហ៊ុនផ្គត់ផ្គង់ ឬក្រុមហ៊ុនផ្សេងទៀត ក្នុងការយល់ព្រមទទួលយកសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដែលស្នើសុំនាំចូល ត្រឡប់ទៅប្រទេសដើម ឬប្រទេសណាផ្សេង វិញបន្ទាប់ពីឈប់ ឬអស់សុពលភាពប្រើប្រាស់ A copy of an agreement or letter or documents indicates the manufacturers or suppliers will accept the radioactive substances/sources to the country of origins or other countries for conditioning after depleted or disused ..................................................០១ ច្បាប់ (1 Copy)
  - ☐ លិខិតធានារបស់នីតិបុគ្គលសាធារណៈ ក្នុងការនាំចេញសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដែលស្នើសុំ ត្រឡប់ទៅប្រទេសដើម ឬប្រទេសណាមួយផ្សេង វិញបន្ទាប់ពីឈប់ ឬអស់សុពលភាពប្រើប្រាស់ Declaration letter issued by Public legal entity to return the radioactive substances/sources to the country of origins or other countries for conditioning after depleted or disused ......................០១ ច្បាប់ (1 Copy)

- សម្រាប់នីតិបុគ្គលឯកជន (ក្រុមហ៊ុន) Private Legal Entity (Company/Firm):
  - ☐ ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ដោយមានការបញ្ជាក់ពីអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច A certified copy of Khmer identification card or passport ..................០១ ច្បាប់ (1 Copy)
  - ☐ ច្បាប់ចម្លងវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិងប័ណ្ណប៉ាតង់ ដោយមានការបញ្ជាក់ពីអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច A certified copy of company's certificate of business registration and Patent ......................................................................០១ ច្បាប់ (1 Copy)
  - ☐ ច្បាប់ចម្លងវិញ្ញាបនបត្រ ឬឯកសារបញ្ជាក់ពីលក្ខណៈបច្ចេកទេសរបស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដែលចេញដោយក្រុមហ៊ុនផលិត ឬក្រុមហ៊ុនផ្គត់ផ្គង់ A copy of certificate or documents on the technical specifications of radioactive substances/sources issued by manufacturer or supplier company ..........................................០១ ច្បាប់ (1 Copy)
  - ☐ កិច្ចព្រមព្រៀង ឬកិច្ចសន្យា ឬឯកសារបញ្ជាក់ពីក្រុមហ៊ុនផលិត ឬក្រុមហ៊ុនផ្គត់ផ្គង់ ឬក្រុមហ៊ុនផ្សេងទៀត ក្នុងការយល់ព្រមទទួលយកសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដែលស្នើសុំនាំចូល ត្រឡប់ទៅប្រទេសដើម ឬប្រទេសណាផ្សេង វិញបន្ទាប់ពីឈប់ ឬអស់សុពលភាពប្រើប្រាស់ A copy of an agreement or letter or documents indicates the manufacturers or suppliers will accept the radioactive substances/sources to the country of origins or other countries for conditioning after depleted or disused ..................................................០១ ច្បាប់ (1 Copy)
  - ☐ លិខិតធានារបស់នីតិបុគ្គលស្នើសុំ ក្នុងការនាំចេញសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ដែលស្នើសុំ ត្រឡប់ទៅប្រទេសដើម ឬប្រទេសណាមួយផ្សេង វិញបន្ទាប់ពីឈប់ ឬអស់សុពលភាពប្រើប្រាស់ Declaration letter issued by legal entity to return the radioactive substances/sources to the country of origins or other countries for conditioning after depleted or disused ......................០១ ច្បាប់ (1 Copy)
  - ☐ កិច្ចសន្យាជួលទីតាំង ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនទ្រព្យ ឬលិខិតអនុញ្ញាតចេញដោយអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច ដើម្បីបញ្ជាក់ពីភាពស្របច្បាប់នៃការអនុញ្ញាតឱ្យប្រតិបត្តិការអាជីវកម្មលើទីតាំងពាក់ព័ន្ធនឹងសារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្មដែលស្នើសុំនាំចូល

Lease agreement or land title/deed or permission letter by competent authority to indicate the legality of operating on the location related to radioactive substance/sources which permission to import is being sought……………………………………………………………០១ ច្បាប់ (1 Copy)

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យសុំនេះនិងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ដូចមានយោងខាងលើ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។ I/We, hereby, declare that the information given in this application including all attached supporting documents are true and correct.

សម្រាប់មន្ត្រីទទួលពាក្យ៖.........................
Official Use Only

ថ្ងៃ..................ខែ.............ឆ្នាំ..............ព.ស...........
.............ថ្ងៃទី.............ខែ............ឆ្នាំ...........
Date: ...................................................
ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ
Signature and Name of Applicant

**ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ០១៧៦.រ.ជ.វបប.ប្រក ចុះថ្ងៃទី០១...ខែមេសា.ឆ្នាំ២០២១**

**ស្តីពី**

**ការគ្រប់គ្រងការនាំចូលនិងការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម**

# ពាក្យសុំលិខិតអនុញ្ញាតប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម

APPLICATION FORM FOR PERMISSION LETTER TO USE OF RADIOACTIVE SUBSTANCES AND RADIOACTIVE SOURCES

| រូបថតបុគ្គលស្នើសុំ<br>Photo of applicant<br>4 x 6 |
|---|

រាល់ព័ត៌មានខាងក្រោមត្រូវបំពេញដោយអ្នកស្នើសុំ The following information is to be filled by the applicant

---

1. **លិខិតអនុញ្ញាតនាំចូល Permission Letter to Import**

☐ គ្មាន No

☐ មាន Yes  លិខិតលេខ Letter No. ................. ចុះថ្ងៃទី Dated: ......................... ចេញដោយ Issued by: ...............................

2. **អំពីអ្នកស្នើសុំ Applicant Information**

☐ នីតិបុគ្គលសាធារណៈ Public Legal Entity

ឈ្មោះក្រសួង-ស្ថាប័ន Institution's Name: .......................................................................................................

